ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ៖ ៣០៦
ចុះថ្ងៃទី ២៤-០២-២០២០

សាលដីកា
លេខ៖ ៦៧ក្រII«វ»
ចុះថ្ងៃទី ១១-៦-២០២០

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍

បង្កើតតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ៖ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤ និងបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

| | | |
|---|---|---|
| លោក | [redacted] | ប្រធានក្រុមប្រឹក្សា |
| ឯកឧត្តម | [redacted] | ចៅក្រមប្រឹក្សា |
| លោកស្រី | [redacted] | ចៅក្រមប្រឹក្សា |

**តំណាងមហាអយ្យការ**

| | | |
|---|---|---|
| លោក | [redacted] | ព្រះរាជអាជ្ញា |

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣០៦ ចុះថ្ងៃទី ២៤-០២-២០២០ លើជនជាប់ចោទ ៖

-ឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរយោធា កន្លែងកំណើតសង្កាត់លេខ៣ ក្រុងភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួន [redacted] កៀនស្វាយ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ[redacted](ស) ប្រពន្ធឈ្មោះ [redacted] (រ) ជានីតិជន ទោសពីមុន គ្មាន។ (ប្តឹងឧទ្ធរណ៍)

-ដីកាបង្គាប់ឃុំខ្លួនលេខ ០០៦ ដ.ក.ប.ឃ.ខ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

-មានមេធាវី [redacted]ហួន, មេធាវី[redacted]សែ, មេធាវី [redacted] ម៉ាច, មេធាវី [redacted]សុភ័ក្ត្រា, មេធាវី [redacted]លី, មេធាវី [redacted] កញ្ញា, មេធាវី [redacted]សៀង, មេធាវី [redacted] ឧត្តម និងមេធាវី [redacted] វ៉ារីន ជាមេធាវីការពារសិទ្ធិ។

ជាប់ចោទពីបទ ៖ លួចលក់អចលនវត្ថុរបស់អ្នកដទៃ ប្រព្រឹត្តនៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជួរហុង ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ មុខរបរ មន្ត្រីរាជការ មានទីលំនៅភូមិព្រែក សង្កាត់ច្បារអំពៅ១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

-មានមេធាវី [redacted] សុផល ជាមេធាវីតំណាង ។

## ងរឿងហេតុមានដូចតទៅ៖

ដើមបណ្ដឹងឈ្មោះ [redacted] ជួរហុង បានគ្រប់គ្រង អាស្រ័យផលនៅលើដីទំហំ ៦៨ហិកតា រួមទាំងដីផ្សេងទៀតដែលខ្លួនបានប្រមូលទិញដោយស្របច្បាប់ពីប្រជាពលរដ្ឋនៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ដោយមានលិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះហត្ថលេខាទទួលស្គាល់នៅអាជ្ញាធរដែនដី ភូមិឃុំដែលគ្រប់គ្រងនៅមូលដ្ឋានផ្ទាល់ ហើយដែលខ្លួនបានគ្រប់គ្រងរហូតមិនដែលអាក់ខាន ចាប់តាំងពីឆ្នាំ ២០១០-២០១២ រហូតដល់បច្ចុប្បន្ននេះមិនដែលអាក់ខានឡើយ ។

ស្រាប់តែនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨ ខ្លួនបានឃើញឈ្មោះ តឹម សុវណ្ណ ទៅបញ្ជាឲ្យគេដឹកបង្គោលថ្មយកទៅដីកកប់នៅលើដីរបស់ខ្លួន ដោយព័ទ្ធចូលក្នុងដីខ្លួនទំហំ ៦៨ហិកតា ពេលនោះខ្លួន និងប្រជាពលរដ្ឋនៅទីនោះចំនួនពីរនាក់ទៀត មានឈ្មោះ [redacted] ឆាង និងឈ្មោះ [redacted] ថា បានឃាត់មិនឲ្យបោះបង្គោលនៅលើដីរបស់ខ្លួន ព្រោះដីខ្លួនមានប្រឡាយព័ទ្ធជុំវិញ ហើយខ្លួនកាន់កាប់ជាយូរមកហើយ ពេលនោះលោក [redacted] សុវណ្ណ បានស្រែកឡូឡាប្រមាថដល់អាយុជីវិតរបស់ឈ្មោះ [redacted] ឆាង ហើយលោក [redacted] ម៉េងឡុង ដែលជាអ្នកទិញដីរបស់ខ្លួនពីឈ្មោះ [redacted] សុវណ្ណ បានឆ្លើយថា គាត់ទិញដីនេះពីលោក[redacted] សុវណ្ណ នៅចុងឆ្នាំ២០១៧ ហើយកាលនោះទឹកលិច ជិះទូកមកមើលមិនបានឃើញជិះទូកមកមើល មិនបានឃើញដីទេ ឃើញតែទឹក ដោយលោក [redacted] សុវណ្ណ អះអាងថា ដីនេះជាដីរបស់ភូមិភាគ ហើយបានលក់ឲ្យ [redacted] ម៉េងឡុង ទំហំ ១២៥ហិចតា ក្នុងមួយហិចតា តម្លៃតែ ២.៥០០$ ប៉ុណ្ណោះ ដោយធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីចុះហត្ថលេខាដល់អាជ្ញាធរស្រុក ហើយឲ្យគាត់បង់ប្រាក់ចំនួន ៩០% ខែកុម្ភៈ ឆ្នាំ២០១៨ ទើបសន្យាចុះបោះបង្គោលព្រំ ហើយបង់ប្រាក់បន្ថែម ១០% បង្គ្រប់ ១០០% ប៉ុន្តែចេះតែមានការពន្យាររហូតដល់ខែឧសភា ឆ្នាំ២០១៨ នេះ ពេលបុណ្យចម្រើនព្រះជន្ម ទើបបានចុះបោះបង្គោល ហើយលោក[redacted] ម៉េងឡុង ក៏បានបញ្ជាក់ដែរថា ពេលចុះមកបោះបង្គោលលើដីនេះ ដែលជាពេលទឹកគោក ទើបគាត់មើលឃើញច្បាស់ថា ដីនេះពិតជាដីរបស់ខ្លួន តាន់ ជួរហុង និងដីរបស់លោក[redacted] ម៉េង ទេ តែឈ្មោះ [redacted] សុវណ្ណ នៅតែអះអាងថា ដីនេះមិនមែនជាដីរបស់ខ្លួន [redacted] ជួរហុង និងឈ្មោះ [redacted] ម៉េង ទេ នៅតែថា ជាដីរបស់ភូមិភាគ ដែលតាមពិត នរណាក៏គេដឹងច្បាស់ថា ដីរបស់ភូមិភាគ គឺស្ថិតនៅចំងាយពីដីរបស់ខ្លួននេះ ៤០០ម៉ែត្រ ទៅ ៥០០ម៉ែត្រ ឯណោះ ។



Scanned with CamScanner

លោក [redacted] ម៉េងឡុង បានប្រាប់ខ្លួនថា ដីនេះគាត់ទិញចុងឆ្នាំ២០១៧ តែអាជ្ញាធរបានហៅមេឃុំឲ្យចុះហត្ថលេខា ដោយចុះថ្ងៃខែ ដាក់ឆ្នាំ២០១៦ ហើយគាត់បានណាត់ខ្លួន [redacted] ជួរហុង, លោក [redacted] ម៉េង និងឈ្មោះ [redacted] ផាន់ណា មកជួបជុំគ្នាពិនិត្យឯកសារនៅផ្សារ TK ជិតរង្វង់មូលទួលគោក ដើម្បីគាត់ទារប្រាក់ពីឈ្មោះ [redacted] សុវណ្ណ វិញ ។

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៨ ខ្លួន និងឈ្មោះ [redacted] ម៉េងឡុង, ឈ្មោះ [redacted] ម៉េង និងឈ្មោះនាង ផាន់ណា ក៏បានមកជួបគ្នា ហើយបាននិយាយពីការហួសចិត្តដែលលោក [redacted] សុវណ្ណ លួចលក់ដីរបស់ខ្លួន និងដីរបស់លោក [redacted] ម៉េង នេះ ។

**-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ÷ ១៨៣ "គ" ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ÷** June/2020

១/.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារ ០១(មួយ)ឆ្នាំ ពីបទ លួចលក់អចលនវត្ថុរបស់អ្នកដទៃ ប្រព្រឹត្តនៅ [redacted] ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

២/.ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] សុវណ្ណ ។ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣/.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ សងសំណងជម្ងឺចិត្តចំនួន ៥០.០០០.០០០ (ហាសិបលាន) រៀល ។

-ច្រានចោលការទាមទារលើសពីនេះ របស់ដើមបណ្តឹងរដ្ឋប្បវេណី ។

៤/.សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**-បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ១៨៣ "គ" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**-បានឃើញ** របាយការណ៍រឿង របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០។

**-បានឃើញ** សេចក្តីសន្និដ្ឋានចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។



Scanned with CamScanner

# នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះសង្ខេបរបាយការណ៍រឿង

-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ (វត្តមាន)

-មេធាវី [redacted] ប៊ុនហួន, មេធាវី [redacted] ថៃសែ, មេធាវី [redacted] ម៉ាច, មេធាវី [redacted] សុភ័ក្រ្តា មេធាវី [redacted] ឈុនលី, មេធាវី [redacted] កញ្ញា, មេធាវី [redacted] យូសៀង, មេធាវី [redacted] ឧត្តម និងមេធាវី [redacted] ភ័រីន ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន)

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជួរហុង (វត្តមាន)

-មេធាវី គា សុផល ជាមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានឆ្លើយថា ៖ ខ្លួនប្ដឹងឧទ្ធរណ៍មកនេះ គឺសុំឲ្យមានការលើកលែងចោទប្រកាន់។ ដីរបស់ខ្លួន គឺស្ថិតនៅក្នុងភូមិកណ្ដាលលើ អញ្ចឹងដីនោះតាំងពីឆ្នាំ ១៩៩៧ ខ្លួនបានសុំគោលការណ៍មេភូមិភាគដែលនៅទីនោះ។ នៅឆ្នាំ១៩៩៨ ខ្លួនបានសុំអាជ្ញាធរកាលហ្នឹង គឺមានការិយាល័យកសិកម្មស្រុក ហើយមេឃុំ និងអភិបាលស្រុក បានធ្វើលិខិតទទួលស្គាល់ខ្លួនដែលឈរជើងនៅទីនោះ ។ កាលហ្នឹងមានគោលការណ៍ពីថ្នាក់លើ ពីក្រសួងការពារជាតិ ឲ្យមកឈរជើងការពារផ្ទះសម្ដេចពីចម្ងាយ ហើយខ្លួនបានធ្វើការកាន់កាប់ និងបង្កបង្កើនផលនៅទីនោះ ។ ដីហ្នឹងគឺខាងឃុំ និងការិយាល័យកសិកម្មស្រុកជាអ្នកប្រគល់ឲ្យជាង ៥០០ហិចតា ខ្លួនមានក្រដាសស្នាម។ ពេលនោះ គេកំណត់ទីតាំងមិនច្បាស់លាស់ តែនៅពេលខ្លួនធ្វើនោះមានពីរឃុំ ទីមួយ គឺឃុំសំរោងធំ ទីពីរ ភូមិកណ្ដាលលើ ឃុំបន្ទាយដែក ព្រោះដីហ្នឹងអាជ្ញាធរពុំទាន់កំណត់ថា ដីកន្លែងណានៅឃុំសំរោងធំ និងដីកន្លែងណានៅឃុំបន្ទាយដែក។ គេប្រគល់ឲ្យខ្លួនក្នុងនាមជំបូង គឺអង្គភាព តែពេលហ្នឹងទើបគាត់បែងចែកតាមភូមិភាគនៅឆ្នាំ១៩៩៨។ ខ្លួនទទួលបានដីពីរកន្លែង មួយកន្លែង ៤៥ហិចតា និងមួយកន្លែងទៀត ៨០ហិចតា។ ដីនេះខ្លួនបានធ្វើការកាន់កាប់រហូតមកដល់ឆ្នាំ២០១៦ ហើយខ្លួនបានធ្វើព្រំប្រហែលកន្លះម៉ែត្រនៅឆ្នាំ១៩៩៩ អញ្ចឹងខ្លួនពុំបានដឹងថា ដីហ្នឹងមានបុគ្គលណាកាន់កាប់នោះទេ ទើបនៅឆ្នាំ២០០៣ ខ្លួនបានឮដំណឹងថាប្រជាពលរដ្ឋដែលជាជនខិលខូចមួយចំនួនបានដើរប្រមូលអត្តសញ្ញាណប័ណ្ណគេ ធ្វើការលួចលក់ដីហ្នឹងអស់ ៣៧៥ហិចតាហើយ ចំពោះដីជាង ៥០០ហិចតា នេះ ។ អញ្ចឹងដល់ឆ្នាំ២០១៦ ខ្លួនបានផ្ទេរសិទ្ធិដីទាំង ១២៥ហិចតានេះ ឲ្យទៅលោក [redacted] ម៉េងឡុង ហើយគាត់បានសុំឲ្យផ្ទេរសិទ្ធិដល់ឃុំព្រោះគាត់ដឹងថា ច្បាប់ក្រោយនេះក្រសួងបានកំណត់ថា បុគ្គលណាដែលទិញដី គឺត្រូវធ្វើការផ្ទេរសិទ្ធិដល់ភូមិឃុំស្រុក។ ពេលនោះលោកអភិបាលស្រុក បានឲ្យខ្លួនទៅជួបសុរិយោដីខេត្តឲ្យបញ្ជាក់ពីប្លង់ថា ដីហ្នឹងនៅភូមិណា ហើយមានជាន់លើដីរបស់អ្នកណាអត់។ ពេលខ្លួនបានទៅជួបខាងសុរិយោដីខេត្ត គាត់បានបញ្ជាក់ថា ដីហ្នឹងគឺនៅភូមិកណ្ដាលលើ ឃុំបន្ទាយដែក។ នៅឆ្នាំ ២០១៨ នេះខ្លួនបានទៅធ្វើការបោះបង្គោលបន្ថែមលើដីនោះ ក៏បានជួបលោក [redacted] ជួរហុង និងលោក [redacted] ម៉េង ហើយគាត់ថា ខ្លួនបានបំពានដីរបស់គាត់ ។ ខ្លួនក៏បាននិយាយជាមួយគ្នា ដោយ

375
150
525



Scanned with CamScanner

ថា ដីនេះគឺជារបស់ខ្លួន គាត់ថា ដីនេះជារបស់គាត់ អញ្ចឹងខ្លួនក៏ថា ឥឡូវទៅនិយាយគ្នានៅស្រុក ទៅដើម្បីដោះស្រាយ។ ចំពោះដី ៨០ហិចតា ទៀត គឺនៅចុងខាងជើង ខ្លួនមានឯកសារតែពុំបានដាក់មកនោះទេ ដោយសារខ្លួននៅក្នុងពន្ធនាគារ គឺពុំអាចយកបាននោះទេ។ ដីនេះខ្លួនបានប្តឹងជំទាស់ទៅខេត្ត ដើម្បីឲ្យគាត់ចុះបញ្ជី ហើយមុនពេលខ្លួនជាប់ពន្ធនាគារនេះ គណៈកម្មការខេត្តបានហៅដោះស្រាយម្តងហើយ គឺពុំទាន់បានសម្រេចថា ដីនេះប្រគល់ឲ្យបុគ្គលណានោះទេ។ ដីខ្លួននៅភូមិកណ្តាលលើ ហើយដីខាងដើមបណ្តឹង គឺស្ថិតនៅក្នុងភូមិខ្សុំ នោះទេ។ ទំនាក់ទំនងរវាងភូមិខ្សុំ ជាមួយភូមិកណ្តាលលើ គឺមានភូមិអង្គរជ័យមួយទៀតស្ថិតនៅចំកណ្តាល។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជូរហុង បានឆ្លើយថា ៖ ពីដើម គឺមានភូមិខ្សុំ កណ្តាលលើ និងកណ្តាលក្រោម ហើយនៅឆ្នាំ២០១២ អាជ្ញាធរបានធ្វើការណែនាំឲ្យធ្វើការបំបែកភូមិខ្សុំចេញជាពីរ គឺមានភូមិខ្សុំ និងភូមិអង្គរជ័យ ហើយចំពោះដីដែលខ្លួនបានទិញប្រជាជនគឺនៅភូមិខ្សុំ និងភូមិអង្គរជ័យ។ គាត់បានមកធ្វើការបោះបង្គោលនៅលើដីខ្លួនទំហំ ៦៨ហិចតា ដោយគាត់អះអាងថា ដីហ្នឹងជារបស់ភូមិភាគ ប៉ុន្តែដីភូមិភាគតាមការពិត គឺនៅឃុំសំរោងធំ មិនមែននៅលើក្នុងឃុំបន្ទាយដែកនោះទេ ហើយក៏ពុំមានដីនៅភូមិកណ្តាលលើដែរ ដោយសារមេភូមិកណ្តាលលើក៏ធ្លាប់ធ្វើលិខិតបដិសេធដែរ ហើយមានលិខិតបំភ្លឺ។ ចំពោះភូមិកណ្តាលលើ និងភូមិខ្សុំ គឺស្ថិតនៅក្នុងឃុំបន្ទាយដែក ហើយខាងស្រុកកៀនស្វាយ ក៏គាត់បានចុះមកពិនិត្យជាក់ស្តែង និងមានកំណត់ហេតុបញ្ជាក់។ គាត់បានបញ្ជាក់ថា គាត់មានអាជ្ញាធរសុរិយោដីដឹងឮថា ដីរបស់គាត់នៅភូមិកណ្តាលលើ ប៉ុន្តែឯកសាររបស់គាត់គ្មានទេ។ ខ្លួនបានដីនេះមកពីការទិញប្រជាពលរដ្ឋ ខ្លួនទៅទិញដីប្រជាពលរដ្ឋ គាត់មានព្រំកំណត់ ហើយខ្លួនពុំមានសិទ្ធិទៅកំណត់ព្រំរបស់ពួកគាត់ទេ។ ពេលខ្លួនទិញដីហ្នឹង គឺខាងអាជ្ញាធរជាអ្នករៀបចំ មានភូមិបាល និងគណៈកម្មការគេចុះទៅពិនិត្យហើយ។ ពេលទិញ ខ្លួនបានធ្វើប្រឡាយធំណាស់លើដីហ្នឹង ។ ពេលខ្លួនធ្វើលិខិតផ្ទេរសិទ្ធិ គឺខ្លួនបានធ្វើលិខិតដោយមានចុះហត្ថលេខានៅឃុំស្រុក។ ចំពោះឯកសារដីទាំងនេះគឺធ្វើឡើងនៅក្នុងឆ្នាំ២០១០ និងឆ្នាំ ២០១២។

## មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋាន

-ទាក់ទងទៅនឹងអង្គហេតុនេះ ដើមឡើយកូនក្តីខ្លួន [redacted] ជូរហុង គាត់បានទិញដីពីប្រជាពលរដ្ឋនៅភូមិខ្សុំនេះនៅឆ្នាំ២០១០ ហើយប្រមូលទិញជាបន្តបន្ទាប់ដល់ឆ្នាំ២០១២ ហើយដីនេះមានទំហំជាង ១០០ហិចតា មិនមែនតែ ៦០ហិចតាជាង ដែលឈ្មោះ [redacted] សុវណ្ណ លួចលក់នោះទេ។ ពីដើមមក គឺមានតែភូមិខ្សុំ ភូមិកណ្តាលលើ ភូមិកណ្តាលក្រោម គឺមានតែបីភូមិទេ ក្រោយមកនៅឆ្នាំ២០១២ គឺមានប្រកាសស្តីពីការបង្កើតភូមិចំនួន ៦៣ នៅខេត្តកណ្តាល បន្ថែមទៀតនៅក្នុងទំព័រលេខ៤ ចំណុចទី៣ និងទី៤ បង្កើតភូមិចំនួន ៣ភូមិ នៅក្នុងឃុំបន្ទាយដែក ដែលភូមិអង្គរជ័យ បំបែកចេញពីភូមិខ្សុំ អញ្ចឹងមុនឆ្នាំ២០១២ គឺពុំមានភូមិអង្គរជ័យនោះទេ តែឆ្នាំ២០១២ គេបំបែកភូមិខ្សុំ ទៅភូមិអង្គរជ័យមួយទៀត ដូច្នេះ ទីតាំងដីគឺអត់ប្តូរទៅណាទេ។ នៅក្នុងសំណុំរឿងនេះ មុននឹងសាលាដំបូងសម្រេចធ្វើការផ្តន្ទាទោសជនជាប់ចោទ គឺគាត់បានធ្វើការស៊ើបអង្កេត,



Scanned with CamScanner

ស្វែងរកភស្តុតាងតាំងពីដំណាក់កាលអយ្យការ ចៅក្រមស៊ើបសួរ រហូតដល់ដំណាក់កាលជំនុំជម្រះ គឺទុកពេលឲ្យជនជាប់ចោទរកភស្តុតាងបញ្ជាក់ថា ដីដែលខ្លួនលក់នេះ គឺជាដីរបស់ខ្លួន ប៉ុន្តែទាំងនៅក្នុងដំណាក់កាលអយ្យការ ចៅក្រមស៊ើបសួរ ក៏ដូចជាដំណាក់កាលសវនាការ គឺដូចពេលនេះ គាត់បានឆ្លើយដដែលថា មានឯកសារបញ្ជាក់ ។ ផ្ទុយទៅវិញចំពោះភស្តុតាង គឺមានតែមួយគត់ ដូចលោកប្រធានលើកបញ្ជាក់ គឺមានតែទំហំ ៤៥ហិចតា នោះទេ ហើយ ៨០ហិចតានោះ គឺឆ្លើយដដែលថា ឯកសារនៅផ្ទះអស់ពេលជាង០១ឆ្នាំមកហើយ។ ទីតាំងដីដែលភូមិភាគគ្រប់គ្រងនោះគឺនៅឃុំសំពោងធំ មិនមែននៅក្នុងឃុំបន្ទាយដែកនោះទេ ។ រហូតមកដល់ពេលនេះ ពុំមានឯកសារណាមួយបញ្ជាក់ថា គេបានបំបែកឃុំ ដូចជាឯកសារបញ្ជាក់ថា គេបានបំបែកភូមិនោះទេ។ ជនជាប់ចោទដែលគាត់លក់ដីរបស់ជនរងគ្រោះនេះ គឺគាត់ពុំមានឯកសារណាបញ្ជាក់ថា ជាដីរបស់គាត់ ឬ ដីរបស់ភូមិភាគណាក៏ពុំមានដែរ គឺមានតែឯកសារដែលបញ្ជាក់ថា គាត់មានដីទំហំ ៤៥ ហិចតា នៅភូមិសំពោងធំ ហើយគាត់បានលក់ដីរហូតដល់ ១២៥ហិចតា ដែលដីនេះគឺចូលទៅក្នុងដីរបស់ឈ្មោះ [redacted] ជួរហុង។ មួយទៀត ខ្លួនសូមជម្រាបជូនក្រុមប្រឹក្សាថា ដីទំហំ ១២៥ ហិចតា គាត់យកទៅលក់ឲ្យឈ្មោ[redacted] ម៉េងឡុង ហើយគាត់យកដី ១២៥ ហិចតា លួចលក់បន្តទៅឲ្យអ្នកដទៃទៀត។ អំពើរបស់គាត់នេះគឺមិនមែនប៉ះពាល់តែជនរងគ្រោះនោះទេ គឺគាត់បានដើរលក់ដីគេអោយទៅអ្នកនេះផងផង អ្នកនោះផង គឺធ្វើឲ្យប៉ះពាល់ដល់អ្នកដទៃជាច្រើន។ មុននឹងសម្រេចគេបានឲ្យភូមិបាល និងអាជ្ញាធរដែនដីចុះទៅពិនិត្យទីតាំងដីទំនាស់ដែលចង្អុលបង្ហាញដោយជនរងគ្រោះ និងជនជាប់ចោទ ។ នៅពេលដែលចង្អុលបង្ហាញតាមឯកសារទៅ គឺខាងអាជ្ញាធរថ្នាក់ក្រោម និងភូមិឃុំ គេទទួលស្គាល់ឯកសាររបស់[redacted]ជួរហុង។ ខ្លួនសំណូមពរ ក្រុមប្រឹក្សាជំនុំជម្រះ មេត្តាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងខេត្តកណ្តាលទុកជាបានការដដែល។

## តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន

អង្គហេតុនេះ តំណាងមហាអយ្យការនៅតែចែកមិនទាន់ដាច់ ជាគំនិតរបស់ខ្លួនដែលជាតំណាងមហាអយ្យការ នៅតែមានយោបល់យល់ឃើញថា រឿងនេះជារឿងរដ្ឋប្បវេណី ដែលជាវិវាទដីធ្លី ពាក់ព័ន្ធទៅនឹងការកាន់កាប់ដី។ វិវាទដីធ្លីពាក់ព័ន្ធទៅនឹងការកាន់កាប់ដីនេះ យើងត្រូវរកឲ្យច្បាស់លាស់សិនថា តើមានឯកសារអ្វីបញ្ជាក់ពីសាលាដំបូងថា ជនជាប់ចោទ ឬដើមបណ្តឹងជាកម្មសិទ្ធិករលើដីនេះសិន ទើបយើងយោងអង្គហេតុនៅក្នុងរឿងនេះដើម្បីធ្វើការវិនិច្ឆ័យលើជនជាប់ចោទនៅពេលក្រោយ ។ ដូចជាលោកចៅក្រមបានសួរដេញដោលលើជនជាប់ចោទ ក៏ដូចជាសេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឲ្យដើមបណ្តឹង និងជនជាប់ចោទ ពីការបែងចែកភូមិក្នុងវិវាទដីធ្លីនេះ នៅតែជាបញ្ហាដដែល។ ពីដើមឡើយ ប្រជាពលរដ្ឋដែលជាអ្នកកាន់កាប់ដីហ្នឹង មានពាក្យស្នើសុំកាន់កាប់ដីធ្លី ហើយមេភូមិ មេឃុំ គាត់ចុះទៅបញ្ជាក់។ នៅមុនឆ្នាំ២០១៣ គឺកាន់កាប់ និងមានវិវាទដូចរឿងនេះអញ្ចឹង ប៉ុន្តែគឺពុំសូវមានសាលាដំបូងណាយករឿងដែលមិនទាន់ចែកដាច់ពីវិវាទដីធ្លីដែលមានប័ណ្ណដូចគ្នានេះ មកធ្វើការចោទប្រកាន់រឿងព្រហ្មទណ្ឌនោះទេ។ នេះជាការយល់ឃើញ និងកត់សម្គាល់របស់ខ្លួនដែលជាវិវាទរដ្ឋប្បវេណី ដែលត្រូវយកមកដោះស្រាយតាម



Scanned with CamScanner

គុលាការរដ្ឋប្បវេណី ហើយបើយកពាក្យស្នើសុំកាន់កាប់នេះ មកបញ្ជាក់ថា ជាកម្មសិទ្ធិរបស់ដើម
បណ្ដឹង ឬជនជាប់ចោទ នោះទេ។ ហេតុដូច្នេះ ហើយនៅក្នុងឆ្នាំ២០១៨ រដ្ឋមន្ត្រីក្រសួងដែនដី គាត់
បានណែនាំនៅពេលដែលប្រជាជនដែលអះអាងថា ជាម្ចាស់កម្មសិទ្ធិលើដី គឺត្រូវមានលិខិតកាន់
កាប់ដីធ្លីរបស់គាត់ ត្រូវមានមេភូមិ មេឃុំ ហើយភូមិបាលស្រុកត្រូវចុះមកធ្វើការពិនិត្យ និងគូស
ប្លង់លើដីដែលខ្លួនបានសុំ ទើបអាចទទួលយកបាន ។ ចំពោះវិវាទនេះ គឺកើតឡើងមុនការ
ណែនាំរបស់រដ្ឋមន្ត្រី ដូច្នេះ ទើបមានវិវាទទាក់ទងទៅនឹងកម្មសិទ្ធិនេះកើតឡើង។ ខ្លួនសូមបញ្ជាក់
ថា វិវាទនេះគឺជាវិវាទរដ្ឋប្បវេណី គួរតែត្រូវឲ្យជនជាប់ចោទ រួចខ្លួនពីបទចោទ ហើយឲ្យគាត់នាំគ្នា
រកថា តើដីនេះជាកម្មសិទ្ធិរបស់អ្នកណាសិន ទើបសម្រេចថា ត្រូវធ្វើម៉េចទៀត។ សូមលោកប្រធាន
និងក្រុមប្រឹក្សាជំនុំជម្រះ ធ្វើការពិចារណា។

## មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋាន

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា ៖ ចំពោះ
-លោក [redacted] ម៉ាច ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា ៖ ចំពោះ
អង្គហេតុក្នុងរឿងនេះ ខ្លួនសុំមិនលើកឡើងទេ ព្រោះមានសំណុំរឿង និងឯកសារបញ្ជាក់ហើយ។
ខ្លួនសុំឯកភាពទាំងស្រុងចំពោះសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ដោយយល់ឃើញថា
វាមានភាពស៊ីសង្វាក់ទៅនឹងរឿងហេតុនេះទាំងស្រុង។ ដើមបណ្ដឹងរដ្ឋប្បវេណីគាត់ថា កូនក្ដីខ្លួន
ឈ្មោះ [redacted] សុវណ្ណ បានលក់ដីគាត់ ទើបមានការផ្ដន្ទាទោសកូនក្ដីខ្លួន។ ប៉ុន្តែ ទាក់ទងទៅនឹង
ភស្តុតាងដែលដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញនេះ គឺមិនទាន់មានលក្ខណៈគ្រប់គ្រាន់តាមផ្លូវ
ច្បាប់នៅឡើយទេ។ ទី១ ដើមបណ្ដឹងរដ្ឋប្បវេណី បានប្ដឹងថា កូនក្ដីខ្លួនរំលោភលើដីរបស់គាត់នោះ
មានចំនួន ៦៨ ហិចតា ដោយសំអាងទៅលើលិខិតផ្ទេរសិទ្ធិដែលគាត់បានធ្វើការទិញលក់កាលពី
ឆ្នាំ២០១០ និងឆ្នាំ២០១២ សួរថា តើគាត់មានប្លង់ដីម៉ាស់ ហើយដីទាំងអស់ហ្នឹងចូលក្នុងប្លង់តែមួយ
ទេ គឺគាត់មិនបានឆ្លើយទៅនឹងសំនួរខ្លួនទេ ព្រោះគាត់អត់មាន។ កាលណាដីធំគឺត្រូវមានប្លង់
ដីម៉ាស់រួម ដែលនៅពេលគេទិញម្ដងហើយ គឺត្រូវបញ្ជាក់ថា តើដីហ្នឹងជាប់គ្នាក្នុងតំបន់តែមួយ។
ទី២ គាត់បានលើកឡើងថា គាត់ទិញពីប្រជាពលរដ្ឋ ដែលប្រជាពលរដ្ឋគាត់មកធ្វើការកាន់កាប់
កាលពីឆ្នាំ២០០០ ឬ ២០០១ យើងឃើញថា នៅដំណាក់កាលនេះ ច្បាប់មានការអភិវឌ្ឍន៍លើការ
គ្រប់គ្រងដែនដីហើយតាំងពីឆ្នាំ១៩៨៩ រដ្ឋបានប្រកាសឲ្យប្រជាពលរដ្ឋមានសិទ្ធិលើកម្មសិទ្ធិ ពេល
ហ្នឹងគេប្រាប់ប្រជាពលរដ្ឋដាក់ពាក្យស្នើសុំកាន់កាប់ដីធ្លី ហើយសួរថា ប្រជាពលរដ្ឋដែលមកធ្វើការ
អះអាងនេះ មានដៃរឬអត់ គឺអត់មានទេ។ នៅឆ្នាំ១៩៩២ រដ្ឋបានធ្វើការចុះបញ្ជីប្លង់កម្មសិទ្ធិ ហើយ
បានចេញច្បាប់ភូមិបាល បានកំណត់ហើយថា ចំពោះភោគៈផ្សេងៗទៀតមិនត្រូវអនុញ្ញាត។ ដល់
ឆ្នាំ២០០៨ គាត់ថាប្រជាពលរដ្ឋបានធ្វើពាក្យស្នើសុំកាន់កាប់ ពាក្យនេះ គ្រាន់តែជាការស្នើសុំទេ
គឺមិនទាន់កំណត់ថា ជាម្ចាស់កម្មសិទ្ធិករលើដីរបស់ខ្លួនកាន់កាប់នោះទេ។ ដូច្នេះ ខ្លួនពុំទាន់កំណត់
ថា ជាម្ចាស់កម្មសិទ្ធិផង យើងបានយកដីទៅលក់ឲ្យដើមបណ្ដឹង ទាំងខ្លួនពុំទាន់មានសិទ្ធិជាកម្ម
សិទ្ធិករលើដីហ្នឹងផង ។ ដើមបណ្ដឹងរដ្ឋប្បវេណី ពុំទាន់ក្លាយទៅជាម្ចាស់កម្មសិទ្ធិករស្របច្បាប់លើ
ដីហ្នឹងទេ គឺគ្រាន់តែអាចក្លាយទៅជាម្ចាស់កម្មសិទ្ធិករដែលមានសិទ្ធិស្ថាពរបាន លុះត្រាតែចុះបញ្ជីដី



Scanned with CamScanner

ថ្មី ។ ពេគាត់មានវិវាទនេះហើយ ទើបគាត់រត់ទៅចុះបញ្ជីដីថ្មី ។ តុលាការផ្តន្ទាទោសកូនក្តីខ្លួន
តាមតែរយៈកំណត់ហេតុចុះពិនិត្យ និងលិខិតបដិសេធរបស់មេភូមិ មេឃុំ ចុះគាត់ចុះហត្ថលេខា
ឲ្យកូនក្តីខ្លួន ហើយគាត់ធ្វើលិខិតបដិសេធ គាត់ក៏ត្រូវជាប់គុកដែរ ។ ខាងមន្ទីរការិយាល័យដែល
ចាប់ឲ្យធ្វើការស្រាវជ្រាវឃើញថា គេចាប់ឲ្យទៅពិនិត្យ មិនមែនទៅអង្គុយនៅផ្ទះមេភូមិ ហើយធ្វើ
ការសម្រេចនោះទេ ហើយកូនក្តីខ្លួនមិនបានចូលរួមទៀត ។ ដូច្នេះ ការឃុំខ្លួនកូនក្តីខ្លួន គឺឈឺចាប់
ណាស់ ឃុំមនុស្សក្នុងគុក ។ ខ្លួនសំណូមពរ សុំឲ្យតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចផុតបទចោទ។

-លោក [redacted] ប៊ុនហួន ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ៖
តាមការសាកសួរ យើងបានឃើញអង្គហេតុរួចទៅហើយ ។ ខ្លួនសុំធ្វើសេចក្តីថ្លែងអំណរគុណ
ដល់តំណាងមហាអយ្យការនាពេលនេះ គឺមានភាពយុត្តិធម៌ក្នុងការជួយរកការពិតជូនកូនក្តីខ្លួន
ច្រើនមែនទែន ហើយខ្លួនមិនដែលបានជួបស្ថានភាពបែបនេះទេ បើយថ្ងៃនេះ ខ្លួនសប្បាយ
ចិត្តព្រោះតំណាងមហាអយ្យការលោកបានពិចារណាច្បាស់ ទាក់ទងទៅនឹងវិវាទព្រហ្មទណ្ឌ ជា
មួយវិវាទរដ្ឋប្បវេណី លោកបានធ្វើសេចក្តីសន្និដ្ឋានរួចហើយថា វិវាទនេះគឺជាវិវាទរដ្ឋប្បវេណី
ដែលស្នើសុំតុលាការមេត្តាពិចារណា ទម្លាក់បទចោទឲ្យកូនក្តីខ្លួននេះសិន ដើម្បីទុកលទ្ធភាពឲ្យ
គាត់តស៊ូក្តីតាមផ្លូវរដ្ឋប្បវេណី ឲ្យដាច់ស្រេចសិន។ លោកក៏បានលើកអំពីឯកសារគតិយុត្តិមួយចំនួន
ដូចជា សេចក្តីណែនាំរបស់ក្រសួងដែនដី យកមកបញ្ជាក់ច្បាស់លាស់។ នៅក្នុងនេះ ខ្លួនសូមធ្វើ
ការកត់សម្គាល់ខ្លះ ព្រោះសហភាតាលោកបានធ្វើសេចក្តីសន្និដ្ឋានរួចហើយ។ ទី១ សំណុំរឿងនេះ
គឺជាវិវាទទៅលើកម្មសិទ្ធិដីធ្លី ដែលយើងបានពិភាក្សាដេញដោលនាពេលនេះ សួរទាំងដើមបណ្តឹង
និងចុងចម្លើយ គ្មានចំណុចមួយណាបញ្ជាក់អំពីកម្មសិទ្ធិដីធ្លី ដែលមានការទទួលស្គាល់ដោយ
អាជ្ញាធរច្បាស់លាស់ថា មានដូចជាវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់
កាប់ដីធ្លី ដើម្បីបញ្ជាក់ថា ខ្លួនជាម្ចាស់កម្មសិទ្ធិច្បាស់លាស់ ក៏ប៉ុន្តែវិវាទដីធ្លីពេលនេះ ភាគីទាំង
សងខាងពុំមានឯកសារណាមួយបញ្ជាក់ច្បាស់លាស់ ជាពិសេសភាគីដើមបណ្តឹងរដ្ឋប្បវេណី មាន
តែឯកសារទិញលក់រវាងប្រជាពលរដ្ឋ ផ្ទេរសិទ្ធិមកឲ្យគាត់ ហើយបានយកមកប្តឹងកូនក្តីខ្លួនពីបទ
ល្មើសព្រហ្មទណ្ឌ។ ចំណុចដែលខ្លួនធ្វើការកត់សម្គាល់មួយទៀត វិវាទនេះមិនទាន់ធ្វើការកំណត់
ច្បាស់ពីភូមិសាស្ត្រ ភាគីកូនក្តីខ្លួនបានបង្ហាញថា គាត់មានដីនៅភូមិកណ្តាលលើ ភាគីម្ខាងទៀត
ថា នៅភូមិខ្សុំ ឯកសារបង្ហាញអំពីចំណុចដាក់ចំ កូនក្តីខ្លួននៅភូមិកៈណ្តាលលើ ។ ច្បាស់លាស់
នៅភូមិកណ្តាលលើ ១២៥ហិចតា មានតែនៅភូមិខ្សុំណា នេះជាចំណុចខ្លួនធ្វើការកត់សម្គាល់។
ទី២ ខ្លួនសុំធ្វើការលើកអំពីអង្គច្បាប់ ដូចខ្លួនសុំបញ្ជាក់ទី១ យើងពិចារណាទៅលើប្រកាសអន្តរ
ក្រសួងលេខ ០២ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និង
គណៈកម្មការសុរិយោដី ពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ចំណុចទី១
គឺចង់មានន័យថា បើវិវាទដែលពាក់ព័ន្ធកម្មសិទ្ធិដីធ្លីដែលមិនទាន់ចុះបញ្ជីសមត្ថកិច្ចរបស់តុលាការ



Scanned with CamScanner

មិនត្រូវពិចារណាចំណុចនេះទេ គឺទុកឲ្យគណៈកម្មការដីធ្លីជាអ្នកដោះស្រាយថា តើអ្នកណាជាម្ចាស់កម្មសិទ្ធិលើដីនោះសិន។ យើងឃើញថា អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ដែលកំណត់ថា មានគណៈកម្មការដោះស្រាយវិវាទដីធ្លីថ្នាក់ស្រុក ខេត្ត ជាតិ សួរថា តើមានគាតមានដោះស្រាយដល់តាមដំណាក់កាលឬនៅ គឺអត់មានទេ។ តាមបញ្ញត្តិមាត្រា ២៥៥ នៃច្បាប់ភូមិបាល បានចែងថា "ជនណាដែលបានលួចលក់ ឬលួចបញ្ចាំអចលនវត្ថុដែលមិនមែនជារបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ដល់ ៣ឆ្នាំ ដោយមិនគិតដល់ព្យសនកម្មដែលបណ្តាលមកពីអំពើរបស់ខ្លួន"។ មានន័យថា លួចលក់របស់អ្នកដទៃ ធ្វើម៉េចបានដឹងថា ជារបស់អ្នកដទៃ ទាល់តែអ្នកឯងមានកម្មសិទ្ធិសិន។ លើសពីនេះទៅទៀត យើងឃើញនៅក្នុងក្រមមាត្រា ៣៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌគេថា វិវាទបញ្ហាបន្ទាន់បង្ខំ និងការបង្អង់មិនទាន់សម្រេច បើសិនមិនទាន់រកឃើញម្ចាស់កម្មសិទ្ធិច្បាស់លាស់។ បើសិនយកសំណុំរឿងនេះមកពិចារណាអំពីទោស គឺច្រើនរឿងណាស់ ។ នៅក្នុងនោះទៀតដែរ ខ្លួនសុំបញ្ជាក់ថាកំណត់ហេតុចុះទៅធ្វើការស្រាវជ្រាវ គឺពុំបានធ្វើសេចក្តីសន្និដ្ឋានបញ្ជាក់ថាដីនេះជារបស់ឈ្មោះ [redacted] ជួរហុង គឺខ្លួនពុំហ៊ានបញ្ជាក់នោះទេ។ ជាចុងក្រោយ ខ្លួនស្នើសុំលោកប្រធាន និងក្រុមប្រឹក្សាជំនុំជម្រះ មេត្តាទម្លាក់បទចោទប្រកាន់ និងធ្វើការដោះលែងកូនក្តីខ្លួនឲ្យមានសេរីភាព។

-លោក [redacted] សុភ័ក្រ្តា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ខ្លួនសុំឯកភាពចំពោះសហភាគា ហើយខ្លួនសុំបង្ហាញខ្លីៗ ទេ គឺទាក់ទងទៅនឹងសេចក្តីសម្រេចកាត់ភូមិ ព្រោះដោយសារទីតាំងរបស់ភាគីដើមបណ្តឹងគាត់ប្តឹងមក គឺនៅភូមិខ្សុំ ហើយដីរបស់កូនក្តីខ្លួនគឺនៅភូមិកណ្តោលលើ ទេ។

## សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានសំណូមពរសុំឲ្យតុលាការលើកលែងចោទប្រកាន់ឲ្យខ្លួន។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ។

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ ។

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។



Scanned with CamScanner

# <u>សាលាឧទ្ធរណ៍ភ្នំពេញ</u>

## <u>យល់ឃើញថា</u> ÷

១/.បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៨៣ "គ" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងមាត្រា ៤៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ទទួលជំនុំជម្រះបាន។

២/.នៅក្នុងកិច្ចពិភាក្សាដេញដោលនាពេលសវនាការ ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានឆ្លើយថា ៖ ខ្លួនប្តឹងឧទ្ធរណ៍មកនេះ គឺសុំឲ្យមានការលើកលែងចោទប្រកាន់។ ដីរបស់ខ្លួន គឺស្ថិតនៅក្នុងភូមិកណ្តោលលើ អញ្ចឹងដីនោះតាំងពីឆ្នាំ១៩៩៧ ខ្លួនបានសុំគោលការណ៍មេភូមិភាគដែលនៅទីនោះ។ នៅឆ្នាំ១៩៩៨ ខ្លួនបានសុំអាជ្ញា ធរកាលហ្នឹង គឺមានការិយាល័យកសិកម្មស្រុក ហើយមេឃុំ និងអភិបាលស្រុក បានធ្វើលិខិតទទួលស្គាល់ខ្លួនដែលឈរជើងនៅទីនោះ ។ កាលហ្នឹងមានគោលការណ៍ពីថ្នាក់លើ ពីក្រសួងការពារជាតិ ឲ្យមកឈរជើងការពារផ្ទះសម្តេចពីចម្ងាយ ហើយខ្លួនបានធ្វើការកាន់កាប់ និងបង្កបង្កើនផលនៅទីនោះ ។ ដីហ្នឹងគឺខាងឃុំ និងការិយាល័យកសិកម្មស្រុកជាអ្នកប្រគល់ឲ្យជាង ៥០០ ហិចតា ខ្លួនមានក្រដាសស្នាម។ ពេលនោះគេកំណត់ទីតាំងមិនច្បាស់លាស់ តែនៅពេលខ្លួនធ្វើនោះមានពីរឃុំ ទីមួយ គឺឃុំសំរោងធំ ទីពីរ ភូមិកណ្តោលលើ ឃុំបន្ទាយដែក ព្រោះដីហ្នឹងអាជ្ញាធរ ពុំទាន់កំណត់ថា ដីកន្លែងណានៅឃុំសំរោងធំ និងដីកន្លែងណានៅឃុំបន្ទាយដែក។ គេប្រគល់ឲ្យខ្លួនក្នុងនាមដំបូង គឺអង្គភាព តែពេលហ្នឹងទើបគាត់បែងចែកតាមភូមិភាគនៅឆ្នាំ១៩៩៨។ ខ្លួនទទួលបានដីពីរកន្លែង មួយកន្លែង ៤៥ហិចតា និងមួយកន្លែងទៀត ៨០ហិចតា។ ដីនេះខ្លួនបានធ្វើការកាន់កាប់រហូតមកដល់ឆ្នាំ២០១៦ ហើយខ្លួនបានធ្វើព្រំប្រហែលកន្លះម៉ែត្រនៅឆ្នាំ១៩៩៩ អញ្ចឹងខ្លួនពុំបានដឹងថា ដីហ្នឹងមានបុគ្គលណាកាន់កាប់នោះទេ ទើបនៅឆ្នាំ២០០៣ ខ្លួនបានឮដំណឹងថាប្រជាពលរដ្ឋដែលជាជនខិលខូចមួយចំនួនបានដើរប្រមូលអត្តសញ្ញាណប័ណ្ណគេ ធ្វើការលួចលក់ដីហ្នឹងអស់ ៣៧៥ហិចតាហើយ ចំពោះដីជាង ៥០០ហិចតា នេះ ។ អញ្ចឹងដល់ឆ្នាំ២០១៦ ខ្លួនបានផ្ទេរសិទ្ធិដីទាំង ១២៥ហិចតានេះ ឲ្យទៅលោក សុខ ម៉េងឡុង ហើយគាត់បានសុំឲ្យផ្ទេរសិទ្ធិដល់ឃុំ ព្រោះគាត់ដឹងថា ច្បាប់ក្រោយនេះក្រសួងបានកំណត់ថា បុគ្គលណាដែលទិញដី គឺត្រូវធ្វើការផ្ទេរសិទ្ធិដល់ភូមិឃុំស្រុក។ ពេលនោះលោកអភិបាលស្រុក បានឲ្យខ្លួនទៅជួបសុរិយោដីខេត្តឲ្យបញ្ជាក់ពីប្លង់ថា ដីហ្នឹងនៅភូមិណា ហើយមានជាន់លើដីរបស់អ្នកណាអត់។ ពេលខ្លួនបានទៅជួបខាងសុរិយោដីខេត្ត គាត់បានបញ្ជាក់ថា ដីហ្នឹងគឺនៅភូមិកណ្តោលលើ ឃុំបន្ទាយដែក។ នៅឆ្នាំ២០១៨ នេះខ្លួនបានទៅធ្វើការបោះបង្គោលបន្ថែមលើដីនោះ ក៏បានជួបលោក [redacted] ជួរហុង និងលោក [redacted] ម៉េង ហើយគាត់ថា ខ្លួនបានបំពានដី



របស់គាត់ ។ ខ្លួនក៏បាននិយាយជាមួយគ្នា ដោយថា ដីនេះគឺជារបស់ខ្លួន គាត់ថា ដីនេះជារបស់គាត់ អញ្ចឹងខ្លួនក៏ថា ឥឡូវទៅនិយាយគ្នានៅស្រុកទៅដើម្បីដោះស្រាយ។ ចំពោះដី ៨០ហិចតាទៀត គឺនៅចុងខាងជើង ខ្លួនមានឯកសារតែពុំបានដាក់មកនោះទេ ដោយសារខ្លួននៅក្នុងពន្ធនាគារ គឺពុំអាចយកបាននោះទេ។ ដីនេះខ្លួនបានប្តឹងជំទាស់ទៅខេត្ត ដើម្បីឲ្យគាត់ចុះបញ្ជី ហើយមុនពេលខ្លួនជាប់ពន្ធនាគារនេះ គណៈកម្មការខេត្តបានហៅដោះស្រាយម្តងហើយ គឺពុំទាន់បានសម្រេចថាដីនេះប្រគល់ឲ្យបុគ្គលណានោះទេ។ ដីខ្លួននៅភូមិកណ្តាលលើ ហើយដីខាងដើមបណ្តឹង គឺស្ថិតនៅក្នុងភូមិខ្ទុំ នោះទេ។ ទំនាក់ទំនងរវាងភូមិខ្ទុំ ជាមួយភូមិកណ្តាលលើ គឺមានភូមិអង្គរជ័យមួយទៀតស្ថិតនៅចំកណ្តាល។

-ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា នេះគ្រាន់តែជាចម្លើយដោះសារដែលគ្មានភស្តុតាងណាបញ្ជាក់ឲ្យក្រុមប្រឹក្សាជំនុំជម្រះ ធ្វើការពិនិត្យ និងសម្រេចឡើយ។ តាមការពិនិត្យលើអង្គហេតុភស្តុតាងពាក់ព័ន្ធនៅក្នុងសំណុំរឿង រួមទាំងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ តាន់ ជូរហុង ចម្លើយរបស់សាក្សីឈ្មោះ [redacted] ឆាង បញ្ជាក់ឲ្យក្រុមប្រឹក្សាជំនុំជម្រះឃើញថា អង្គហេតុនៃការលួចលក់អចលនវត្ថុរបស់អ្នកដទៃ ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ នេះពិតជាកើតឡើងប្រាកដមែន ដោយសារតាមភស្តុតាងដែលជាលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៦១៥ សកស ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ បញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ដែលជាភាគីអ្នកលក់ បានធ្វើការផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីទំហំ ១.២៥០.០០០,៤៧ ម៉ែត្រការ៉េ ទៅឲ្យឈ្មោះ [redacted] ម៉េងឡុង ដែលជាភាគីអ្នកទិញ ដោយជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានអះអាងថា ដីទាំងអស់នេះជាកម្មសិទ្ធិរបស់ខ្លួន ។ ប៉ុន្តែជាក់ស្តែងជនជាប់ចោទរូបនេះ គឺពុំមានដីរហូតដល់ទំហំ ១.២៥០.០០០,៤៧ ម៉ែត្រការ៉េ ឡើយ ព្រោះតាមពាក្យស្នើសុំដី ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៨ និងលិខិតប្រគល់ដីលេខ ៧១៦/៩៨ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៨ បញ្ជាក់ឲ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ គឺមានដីទំហំតែចំនួន ៤៥ហិចតា ប៉ុណ្ណោះ ដែលទទួលបានពីខាងការិយាល័យកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទស្រុកកៀនស្វាយ ជាអ្នកប្រគល់ឲ្យ។ ផ្ទុយទៅវិញ តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជូរហុង បានឆ្លើយបញ្ជាក់ថា គាត់បានមកធ្វើការបោះបង្គោលនៅលើដីខ្លួនទំហំ ៦៨ ហិចតា ដោយគាត់អះអាងថាដីហ្នឹងជារបស់ភូមិភាគ ប៉ុន្តែដីភូមិភាគតាមការពិត គឺនៅឃុំសំរោងធំ មិនមែននៅលើក្នុងឃុំបន្ទាយដែកនោះទេ ហើយក៏ពុំមានដីនៅភូមិកណ្តាលលើដែរ ដោយសារមេភូមិកណ្តាលលើ ក៏ធ្លាប់ធ្វើលិខិតបដិសេធដែរ ហើយមានលិខិតបំភ្លឺ។ ចំពោះភូមិកណ្តាលលើ និងភូមិខ្ទុំ គឺស្ថិតនៅក្នុងឃុំបន្ទាយដែក ហើយខាងស្រុកកៀនស្វាយក៏គាត់បានចុះមកពិនិត្យជាក់ស្តែងនិងមានកំណត់ហេតុបញ្ជាក់។ ខ្លួនបានដីនេះមកពីការទិញប្រជាពលរដ្ឋ ខ្លួនទៅទិញដីប្រជាពលរដ្ឋគាត់មានព្រំកំណត់របស់គេ ហើយខ្លួនពុំមានសិទ្ធិទៅកំណត់ព្រំរបស់ពួកគាត់ទេ ។ ពេលខ្លួនទិញដីហ្នឹងគឺខាងអាជ្ញាធរជាអ្នករៀបចំមានភូមិបាល និងគណៈកម្មការគេចុះទៅពិនិត្យហើយ។



Scanned with CamScanner

-ត្រង់ចំណុចនេះ មានភាពស៊ីសង្វាក់ទៅនឹងលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ពីប្រជាពលរដ្ឋមកឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជួរហុង។ លិខិតបដិសេធជាផ្លូវការ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ របស់លោក ក្រូច លីស មេភូមិកណ្តាលលើ និងរបស់លោក ឃួន គង់ ជាអតីតមេឃុំបន្ទាយដែក ដែលមានខ្លឹមសារថា "ខ្លួនសូមធ្វើការបដិសេធទាំងស្រុងចំពោះប្លង់បង្ហាញទីតាំងដីឈ្មោះ [redacted] ម៉េងឡុង ដែលឈ្មោះ [redacted] សុវណ្ណ បានលក់និងផ្ទេរសិទ្ធិឲ្យទៅឈ្មោះ សុខ ម៉េងឡុង មានទំហំដី ១.២៥០.០០០,៨៧ ម៉ែត្រក្រឡា។ មូលហេតុៈ ឈ្មោះ [redacted] សុវណ្ណ បានលួចដីរបស់ឈ្មោះ [redacted] ជួរហុង, ឈ្មោះ [redacted] ស្រីធំ និងឈ្មោះ [redacted] ម៉េង ដែលដីនោះស្ថិតនៅភូមិខ្ពុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ដោយឈ្មោះ [redacted] សុវណ្ណ បានកុហកថា ដីនោះជាដីរបស់អង្គភាពភូមិភាគ មិនមានពាក់ព័ន្ធដីប្រជាពលរដ្ឋណានោះទេ"។ តាមលិខិតបំភ្លឺ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ របស់លោក [redacted] គង់ ជាអតីតមេឃុំ បានបញ្ជាក់ថា ដីដែលឈ្មោះ [redacted] សុវណ្ណ បានលួចលក់ និងផ្ទេរសិទ្ធិអោយទៅឈ្មោះ [redacted] ម៉េងឡុង ក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់ លេខ ៦២២ ប.ជ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ដែលមានទំហំដី ១.២៥០.០០០,៨៥ ម៉ែត្រក្រឡា នោះការពិតគឺជាដីរបស់ឈ្មោះ [redacted] ជួរហុង និងឈ្មោះ [redacted] ស្រីធំ ដែលគាត់បានកាន់កាប់ និងប្រើប្រាស់អាស្រ័យផលតាំងពីឆ្នាំ២០១០ មកម្ល៉េះ។

-ដោយឡែកចំពោះលិខិតលេខ ៧២៦/៩៨ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៨ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានស្នើសុំបញ្ចូលជាភស្តុតាងនៅក្នុងសំណុំរឿង តាមពាក្យស្នើសុំបញ្ចូលភស្តុតាង ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ នេះ ដើម្បីបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ពិតជាមានដីទំហំ ៨០ ហិចតាថែមទៀតនោះ។ ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា លិខិតនេះ គឺមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានយកមកដាក់ក្រោយពេលបញ្ចប់កិច្ចភាក្សាដេញដោល នាពេលសវនាការ ហើយតាំងពីដំណាក់អយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះ នៃតុលាការព្រហ្មទណ្ឌថ្នាក់ក្រោម គឺជនជាប់ចោទពុំបានធ្វើការបង្ហាញឯកសារនេះទេ ដើម្បីបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិដែលខ្លួនមានទៅលើដីទំហំ ៨០ហិចតា ឡើយ។ ម្យ៉ាងទៀត លិខិតនេះ គឺជាឯកសារថតចម្លង ដោយពុំមានឯកសារច្បាប់ដើម ដើម្បីធ្វើការផ្ទៀងផ្ទាត់ នោះទេ។ តាមបញ្ញត្តិមាត្រា ៣២១ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា "តុលាការថ្លឹងថ្លែងដោយឥស្សរចិត្ត អំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន។ តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ"។ ដូច្នេះ លិខិតលេខ ៧២៦/៩៨ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៨ ដែលមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានស្នើសុំបញ្ចូលជាភស្តុតាងនៅក្នុងសំណុំរឿងតាមពាក្យស្នើសុំបញ្ចូលភស្តុតាង ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ នេះគឺពុំមានមូលដ្ឋានគតិយុត្តិឲ្យក្រុមប្រឹក្សាជំនុំជម្រះធ្វើការពិនិត្យ និងពិចារណាឡើយ។//



Scanned with CamScanner

៣/.ផ្អែកតាមអង្គហេតុខាងលើនេះបញ្ជាក់ឲ្យឃើញថា ដីទំហំ ១.២៥០.០០០,៤៥ ម៉ែត្រការ៉េ ដែលជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានលក់ឲ្យទៅឈ្មោះ [redacted] ម៉េងឡុង នេះ គឺមានចំនួន ៦៨ ហិចតា ជាដីកម្មសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាកដមែន ដែលនេះជាទម្រង់មួយនៃអំពើ មានធាតុផ្សំ និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ពីបទៈ លួចលក់អចលនវត្ថុរបស់អ្នកដទៃ តាមបញ្ញត្តិមាត្រា ២៥៥ នៃច្បាប់ភូមិបាល ដែលបានចែងថា "ជនណាដែលបានលួចលក់ ឬលួចបញ្ចាំអចលនវត្ថុដែលមិនមែនជារបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ៣ (បី) ឆ្នាំ ដោយមិនគិតដល់ព្យសនកម្មដែលបណ្ដាលមកពីអំពើរបស់ខ្លួន" ។

៤/.មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ពីបទៈ លួចលក់អចលនវត្ថុរបស់អ្នកដទៃ ប្រព្រឹត្តនៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ២៥៥ នៃច្បាប់ភូមិបាល។

៥/.តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បានធ្វើសេចក្ដីសន្និដ្ឋានថា ៖ អង្គហេតុនេះ តំណាងមហាអយ្យការនៅតែចែកមិនទាន់ដាច់ ជាគំនិតរបស់ខ្លួនជាតំណាងមហាអយ្យការនៅតែមានយោបល់យល់ឃើញថា រឿងនេះជារឿងរដ្ឋប្បវេណី ដែលជាវិវាទដីធ្លី ពាក់ព័ន្ធទៅនឹងការកាន់កាប់ដី។ វិវាទដីធ្លីពាក់ព័ន្ធទៅនឹងការកាន់កាប់ដីនេះ យើងត្រូវរកឲ្យច្បាស់លាស់សិនថា តើមានឯកសារអ្វីបញ្ជាក់ពីសាលាដំបូងថា ជនជាប់ចោទ ឬដើមបណ្ដឹង ជាកម្មសិទ្ធិករលើដីនេះសិន ទើបយើងយោងអង្គហេតុនៅក្នុងរឿងនេះដើម្បីធ្វើការវិនិច្ឆ័យលើជនជាប់ចោទនៅពេលក្រោយ ។ ដូចជាលោកចៅក្រមបានសួរដេញដោលលើជនជាប់ចោទ ក៏ដូចជាសេចក្ដីសន្និដ្ឋានរបស់មេធាវីតំណាងឲ្យដើមបណ្ដឹង និងជនជាប់ចោទ ពីការបែងចែកភូមិក្នុងវិវាទដីធ្លីនេះ នៅតែជាបញ្ហាដដែល។ ពីដើមឡើយប្រជាពលរដ្ឋដែលជាអ្នកកាន់កាប់ដីហ្នឹង មានពាក្យស្នើសុំកាន់កាប់ដីធ្លី ហើយមេភូមិ មេឃុំ គាត់ចុះទៅបញ្ជាក់។ នៅមុនឆ្នាំ២០១៣ គឺកាន់កាប និងមានវិវាទដូចរឿងនេះអញ្ចឹង ប៉ុន្តែគឺពុំសូវមានសាលាដំបូងណាយករឿងដែលមិនទាន់ចែកដាច់ពីវិវាទដីធ្លីដែលមានប័ណ្ណដូចគ្នានេះ មកធ្វើការចោទប្រកាន់រឿងព្រហ្មទណ្ឌនោះទេ។ នេះជាការយល់ឃើញ និងកត់សម្គាល់របស់ខ្លួនដែលជាវិវាទរដ្ឋប្បវេណី ដែលត្រូវយកមកដោះស្រាយតាមតុលាការរដ្ឋប្បវេណី ហើយបើយកពាក្យស្នើសុំកាន់កាប់នេះមកបញ្ជាក់ថា ជាកម្មសិទ្ធិរបស់ដើមបណ្ដឹង ឬជនជាប់ចោទ នោះទេ។ ហេតុដូច្នេះហើយ នៅក្នុងឆ្នាំ២០១៨ រដ្ឋមន្ត្រីក្រសួងដែនដី គាត់បានណែនាំនៅពេលដែលប្រជាជនដែលអះអាងថា ជាម្ចាស់កម្មសិទ្ធិលើដី គឺត្រូវមានលិខិតកាន់កាប់ដីធ្លីរបស់គាត់ ត្រូវមានមេភូមិ មេឃុំ ហើយភូមិបាលស្រុកត្រូវចុះមកធ្វើការពិនិត្យ និងគូសប្លង់លើដីដែលខ្លួនបានសុំ ទើបអាចទទួលយកបាន ។ ចំពោះវិវាទនេះ គឺកើតឡើងមុនការណែនាំរបស់រដ្ឋមន្ត្រី ដូច្នេះ ទើបមានវិវាទទាក់ទងទៅនឹងកម្មសិទ្ធិនេះកើតឡើង។ ខ្លួនសូមបញ្ជាក់ថា វិវាទនេះគឺជាវិវាទរដ្ឋប្បវេណី គួរតែត្រូវឲ្យជនជាប់ចោទ រួចខ្លួនពីបទចោទ ហើយឲ្យគាត់នាំគ្នារកថា តើដីនេះជាកម្មសិទ្ធិរបស់អ្នកណាសិន ទើបសម្រេចថា ធ្វើម៉េចទៀត។ សូមលោកប្រធាន និងក្រុមប្រឹក្សាជំនុំជម្រះ ធ្វើការពិចារណា។



Scanned with CamScanner

+ [redacted] [illegible]

ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ពុំមានលក្ខណៈត្រឹមត្រូវនោះទេ ដោយសារនៅក្នុងរឿងនេះ គឺពុំមែនជាវិវាទទាក់ទងទៅនឹងការទាមទារកម្មសិទ្ធិឡើយ គឺជាអង្គហេតុដែលកើតចេញពីសកម្មភាពជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានលួចលក់អចលនវត្ថុរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជូរហុង ហើយក្រុមប្រឹក្សាជំនុំជម្រះ បានរកឃើញពិរុទ្ធភាពចំពោះជនជាប់ចោទឈ្មោះ [redacted] នេះពីបទៈ លួចលក់អចលនវត្ថុរបស់អ្នកដទៃ ដូចមានបញ្ជាក់នៅក្នុងសំរាំងហេតុទី ២ និងទី៣ ខាងលើរួចហើយ។

៦/.ការដែលដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដោយដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំតម្កល់សាលក្រមរបស់សាលាដំបូង ទុកជាបានការ។

-ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា មានលក្ខណៈត្រឹមត្រូវ គប្បី ពិចារណា និងសម្រេច។

៧/.ការដែលជនជាប់ចោទ ក៏ដូចជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ស្នើសុំសាលាឧទ្ធរណ៍សម្រេចឲ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ រួចខ្លួនពីបទចោទប្រកាន់ ដោយលើកមូលហេតុថាសំណុំរឿងនេះគឺជាវិវាទទៅលើកម្មសិទ្ធិដីធ្លី កម្មសិទ្ធិដីធ្លីដែលយើងបានពិភាក្សាដេញនាពេលនេះសួរទាំងដើមបណ្តឹង និងចុងចម្លើយ គ្មានចំណុចមួយណាបញ្ជាក់អំពីកម្មសិទ្ធិដីធ្លីដែលមានការទទួលស្គាល់ដោយអាជ្ញាធរច្បាស់លាស់ថាមានដូចជាវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី ដើម្បីបញ្ជាក់ថាខ្លួនជាម្ចាស់កម្មសិទ្ធិច្បាស់លាស់ ក៏ប៉ុន្តែវិវាទដីធ្លីពេលនេះភាគីទាំងសង់ខាង ពុំមានឯកសារណាមួយបញ្ជាក់ច្បាស់លាស់ ជាពិសេសភាគីដើមបណ្តឹងរដ្ឋប្បវេណី មានតែឯកសារទិញលក់រវាងប្រជាពលរដ្ឋ ផ្ទេរសិទ្ធិមកឲ្យគាត់ ។ ទាក់ទងទៅនឹងភស្តុតាងដែលដើមបណ្តឹងរដ្ឋប្បវេណី បានបង្ហាញនេះ គឺមិនទាន់មានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់នោះទេ។ ការទិញលក់ដីរវាងប្រជាពលរដ្ឋ ជាមួយដើមបណ្តឹងរដ្ឋប្បវេណី គឺពុំមានបានធ្វើប្លង់ដីម៉ាស់ ឡើយ។ ទីតាំងរបស់ភាគីដើមបណ្តឹងគាត់ប្តឹងមក គឺនៅភូមិខ្ញុំ ហើយដីរបស់កូនក្តីខ្លួនគឺនៅភូមិកណ្តាលលើនោះទេ។

[redacted]

-ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថាៈ ពុំមានលក្ខណៈត្រឹមត្រូវឡើយ ដោយសារអង្គហេតុដែលជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានប្រព្រឹត្តកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ នេះ គឺពុំមែនជាវិវាទរដ្ឋប្បវេណី ដូចជាការអះអាងរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ ឡើយ។ ផ្អែកតាមភស្តុតាងពាក់ព័ន្ធ ក៏ដូចជាដីកាបង្គាប់ឲ្យស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុលេខ ០០១/១៨ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់តំណាងអយ្យការ ដែលបានសម្រេច "បង្គាប់មកលោកប្រធានការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកកៀនស្វាយ ចុះធ្វើការស្រាវជ្រាវអំពីៈ ក.សណ្ឋានអចលនវត្ថុ ខ.ទំនាក់ទំនង និង គ.ការកាន់កាប់ ព្រមទាំងស្ថានភាពផ្សេងៗ នៃអចលនវត្ថុដែលមានទំហំ ១.២៥០.០០០,៨៧ម៉ែត្រការ៉េ ដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១០ (ចំនួន១៩ច្បាប់) និងលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ (ចំនួន០១ច្បាប់)"។ តាមលិខិតលេខ ១៩៧



Scanned with CamScanner

ជនសកកស្ម ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុកកៀនស្វាយ ស្តីពី ការចុះស្រាវជ្រាវ អំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ ដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីចំនួន ១៩ ច្បាប់ស្ថិតនៅឃុំបន្ទាយដែក ស្រុកកៀនស្វាយ រួមទាំងកំណត់ហេតុ ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៨ បញ្ជាក់ឲ្យឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជួរហុង ពិតជាមានអត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិចំពោះដីទំហំ ៦៨ហិចតា ដែលជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានលួចលក់នោះប្រាកដមែន។

-ការទិញលក់ដីរវាងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជួរហុង ជាមួយប្រជាពលរដ្ឋ គឺធ្វើឡើងទៅលើដីប្រភេទប្លង់ទន់ ដែលពុំមិនមែនជាដីត្រូវបានចុះបញ្ជីកម្មសិទ្ធិដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ នោះឡើយ ។ ដូច្នេះ ចំពោះការធ្វើផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់និងអាស្រ័យផល គឺអាចធ្វើត្រឹមតែមេភូមិ មេឃុំ ដោយពុំចាំបាច់ធ្វើការផ្ទេរកម្មសិទ្ធិ និងធ្វើប្លង់ដីម៉ាស់រហូតដល់សុរិយោដី ឡើយ។

-ចំពោះការលើកឡើងរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បញ្ជាក់ថា ទីតាំងរបស់ភាគីដើមបណ្តឹង គាត់ប្តឹងមកគឺនៅភូមិខ្សុំ ហើយដីរបស់កូនក្តីខ្លួន គឺនៅភូមិកណ្តាលលើនោះទេ។ ត្រង់ចំណុចនេះ គឺត្រូវបានមេធាវីតំណាងអោយដើមបណ្តឹងរដ្ឋប្បវេណី បញ្ជាក់ហើយថា ពីដើមឡើយមកគឺមានតែភូមិខ្សុំ ភូមិកណ្តាលលើ ភូមិកណ្តាលក្រោម គឺមានតែបីភូមិទេ ក្រោយមកនៅឆ្នាំ ២០១២ គឺមានប្រកាសស្តីពីការបង្កើតភូមិចំនួន ៦៣ នៅខេត្តកណ្តាល បន្ថែមទៀត នៅក្នុងទំព័រលេខ៤ ចំណុចទី៣ និងទី៤ បង្កើតភូមិចំនួន ៣ភូមិ នៅក្នុងឃុំបន្ទាយដែក ដែលភូមិអង្គរជ័យបំបែកចេញពីភូមិខ្សុំ អ៊ីចឹងមុនឆ្នាំ២០១២ គឺពុំមានភូមិអង្គរជ័យនោះទេ តែឆ្នាំ២០១២ គេបំបែកភូមិខ្សុំ ទៅភូមិអង្គរជ័យមួយទៀត ដូច្នេះ ទីតាំងដីគឺអត់ប្តូរទៅណាទេ។

៨/.សាលក្រមព្រហ្មទណ្ឌលេខ ១៨៣ "គ" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល សម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បី សម្រេចតម្កល់ ទុកជាបានការ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១/ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២/តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៨៣"គ" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការ ។

៣/បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់។/.



Scanned with CamScanner

៤/សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

-ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា៖ [redacted] | ហត្ថលេខា៖ [redacted], [redacted] | ហត្ថលេខា៖ [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ សៅរ៍ ០៧ កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២០

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner